# ខ្លឹមសារសង្ខេប សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ លោក ឡូន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព , D55/I/8, ២៦ ខែ សីហា ឆ្នាំ ២០០៨

**១.ពាក្យគន្លឹះ៖** មោឃៈភាព

**២. នីតិវិធី៖** សហមេធាវីស្នើឲ្យអង្គបុរេជំនុំជម្រះ មោឃភាព កិច្ចស៊ើបអង្កេត និងដកចេញពីសំណុំរឿង នូវសេចក្តីថ្លែងការណ៍ដែលមានបញ្ហា និងស្នើឲ្យទទួលយកសំណើនេះ ដោយសារមានហេតុផល និង មូលដ្ឋានរឹងមាំ។ អនុលោមតាមនីតិវិធី សហមេធាវីស្នើឲ្យអនុលោមតាមមោឃភាពចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញា អះអាងថា បញ្ហានេះ ពាក់ព័ន្ធនឹងនីតិវិធី ដែលសំណើនេះគួរត្រូវបានបដិសេធ។

## ៣. សំអាងហេតុ និងសេចក្តីសម្រេច

**ក.** វិធានផ្ទៃក្នុង ត្រូវបានធ្វើឡើងសម្រាប់ **អវតក** ដោយដាក់បញ្ចូលនូវបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលជាឯកសារចម្បងសម្រាប់កំណត់នីតិវិធីនៅចំពោះមុខ អវតក។ អាស្រ័យហេតុនេះ ក្នុងករណីមានភាពខុសគ្នារវាង ក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុងនៃ អវតក វិធានផ្ទៃក្នុង មានអាទិភាព។ ជានីតិវិធី ភាគីត្រូវធ្វើសំណើដោយមានសំអាងហេតុ ដាក់ទៅសហចៅក្រមស៊ើបអង្កេត ស្នើឲ្យបញ្ជូនទៅអង្គបុរេជំនុំជម្រះ។ តាមវិធានផ្ទៃក្នុង ខុសពីការលើឡើងរបស់សហមេធាវីជនជាប់ចោទ សហចៅក្រមស៊ើបអង្កេត មិនមែនដើរតួត្រឹមតែជាច្រកទទួលនិងបញ្ជូនបន្តនូវញត្តិនោះទេ សហចៅក្រម ត្រូវពិនិត្យ ហើយត្រូវផ្តល់សម្អាងហេតុ ក្នុងករណីដែលបដិសេធញត្តិសុំមោឃភាព។

**ខ.** ក្នុងដំណាក់កាលពិនិត្យមើលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធញត្តិសុំមោឃភាព អង្គជំនុំជម្រះក៏ត្រូវពិនិត្យមើលដែរថា **ក.** តើបានផ្តល់ហេតុផលគ្រប់គ្រាន់។ **ខ.** តើពាក់ព័ន្ធនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍ និងថាតើញត្តិនោះ គ្មានមូលដ្ឋានច្បាស់ក្រឡែត។ សម្រាប់ខ្លឹមសារ អង្គបុរេត្រូវពិនិត្យមើលថា កិច្ចស្នើសុំមោឃភាព នោះមានវិការៈ និងប៉ះដល់សិទ្ធិអ្នកស្នើសុំដែរឬទេ? ភាគី ត្រូវបង្ហាញឲ្យជាក់លាក់ថា ផ្នែកណាមួយដែលខ្លួន ចង់ឲ្យមានមោឃភាព នេះដោយសារ អង្គបុរេ មិនអាចផ្តើមដោយខ្លួនឯងថា កិច្ចណាមួយត្រូវគ្មានសុពលភាព។ វិធានទី ៤៨ នៃវិធានផ្ទៃក្នុង អវតក កប្រើពាក្យ “បំពានសិទ្ធិ” តែមាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បើពាក្យ “ប៉ះពាល់ផលប្រយោជន៍” (harmed interest)។ អង្គបុរេ

បានបកស្រាយថា *ការបំពានសិទ្ធិគឺជាការប៉ះពាល់ដល់ផលប្រយោជន៍*។ ភ្ជាប់នឹងចំណុចនេះ តាមមាត្រា២ (៣.ក) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ មានសិទ្ធិទទួលបានដំណោះស្រាយមានប្រសិទ្ធភាព ក្នុងករណីមានការបំពានសិទ្ធិ។ ការបំពានសិទ្ធិ ជាវិការៈនីតិវិធី ដូចនេះកិច្ចនោះ ត្រូវតែមោឃភាព (ដំណោះស្រាយ)។

**គ.** បន្ទាប់ពីបានពិនិត្យ លើពាក្យសុំមោឃភាពពាក់ព័ន្ធនឹងការសម្ភាសជនជាប់ចោទដោយសហចៅក្រមស៊ើបអង្កេត អង្គបុរេ រកមិនឃើញថា សហចៅក្រមស៊ើបអង្កេតប្រព្រឹត្តនូវវិការៈនីតិវិធីទេ។

**៤. កំណត់សំគាល់ (ខ្លឹមសារល្អសម្រាប់ដកស្រង់)**

អង្គបុរេជំនុំជម្រះយល់ឃើញថា *សេចក្តីសម្រេចទាំងអស់របស់តុលាការតម្រូវឲ្យផ្តល់នូវសម្អាងហេតុ ដោយសារវាជាបទដ្ឋានអន្តរជាតិ*។ ដូច្នេះ ដីការបស់សហចៅក្រមស៊ើបអង្កេត ស្តីពី សំណើសុំឲ្យអង្គបុរេជំនុំជម្រះទទួលយករឿងក្តីមកជំនុំជម្រះនេះ ដាច់ខាតត្រូវរៀបរាប់ហេតុផលចំពោះការទទួល ឬការបដិសេធសំណើនេះ (កថាខ័ណ្ឌទី២១)។

*វិធាន៤៨ នៃវិធានផ្ទៃក្នុងចែងអំពីមូលដ្ឋាននៃការបដិសេធ ឬទទួលយកពាក្យសុំមោឃភាពកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះ អាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធាន បញ្ញត្តិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំតែប៉ុណ្ណោះ* (កថាខ័ណ្ឌទី២២)។

*សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការពិនិត្យពាក្យសុំនេះ ដោយផ្អែកលើមូលដ្ឋានចំនួនពីរៈ (១) វត្តមាននៃមោឃភាពនីតិវិធី។ និងទី(២) នៅពេលមានមោឃភាពនីតិវិធីមែននោះ នឹងមានការរំលោភសិទ្ធិរបស់ភាគីដែលធ្វើពាក្យសុំ។ ចំពោះបណ្តឹងឧទ្ធរណ៍នៅចំពោះមុខខ្លួនទាពេលបច្ចុប្បន្ននេះ អង្គបុរេជំនុំជម្រះ ត្រូវពិនិត្យមើលសារជាថ្មីនូវការពិនិត្យស្រាវជ្រាវរបស់សហចៅក្រមស៊ើបអង្កេត* (កថាខ័ណ្ឌទី២៣)។

*នៅពេលមានការរំលោភសិទ្ធិក្នុងអំឡុងពេលប្រមូលភស្តុតាង ភស្តុតាងទាំងនោះ នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ មិនត្រូវបានចាត់ទុកថា មិនអាចទទួលយកបានដោយស្វ័យប្រវត្តិនោះទេ។ ប៉ុន្តែ វិធីសាស្ត្រ និងកាលៈទេសៈជុំវិញការប្រមូលភស្តុតាង ភាពជឿជាក់របស់ភស្តុតាងនោះ ព្រមទាំងផលប៉ះពាល់លើផលប្រយោជន៍នៃកិច្ចដំណើរការនីតិវិធី នឹងសម្រេចពីភាពដែលអាចទទួលយកភស្តុតាងនោះ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនត្រូវពិចារណាកត្តាទាំងនេះ នៅពេលពិចារណាថា បញ្ហាមោឃភាពនីតិវិធី គឺជាដំណោះស្រាយដ៏មានប្រសិទ្ធភាពចំពោះការរំលោភបំពាន* (កថាខ័ណ្ឌទី៤១)។

**ទស្សនៈទាំងស្រុងសូមមើលៈ** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ លោក **នួន ជា** ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព , D55/I/8, ២៦ ខែ សីហា ឆ្នាំ ២០០៨